# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

Royal Angkor
RESORT & SPA
Siem Reap — Kingdom of Cambodia

## កិច្ចព្រមព្រៀង
## រវាងនិយោជក និង និយោជិតក្នុងការព្យួរអាជីវកម្មបណ្ដោះអាសន្នរបស់សណ្ឋាគារ
## រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា

ខ្ញុំបាទ ផាត់ សុគន្ធ ភេទ ប្រុស សញ្ជាតិ ខ្មែរ ជាអនុប្រធានគ្រប់គ្រងទូទៅក្នុងសណ្ឋាគារ **រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា** ដែលមានទីតាំងស្ថិតនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ដែលជាតំណាងឲ្យ គាគី "ក"។

និយោជិតទាំងអស់ដែលបំរើការងារនៅក្នុង សណ្ឋាគារ រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា ដែលមានទីតាំងស្ថិតនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ដែលជាតំណាងឲ្យ គាគី "ខ"។

សណ្ឋាគារ **រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា** នឹងត្រូវផ្អាកដំណើរការអាជីវកម្មជាបណ្ដោះអាសន្ន ចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ដោយសារសណ្ឋាគារ កំពុងជួបប្រទះគ្មានភ្ញៀវស្នាក់នៅដែលបណ្ដាលមកពីវិបត្តិសកលនៃមេរោគកូវីត១៩ ជាហេតុធ្វើឲ្យសណ្ឋាគារគ្មានប្រាក់ចំណូលដើម្បីប្រតិបត្តការអាជីវកម្មទៀតបាន។

ដូចច្នេះទើបក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ បុគ្គលិក ចំនួន ២នាក់ ចំពោះការព្យួរកិច្ចសន្យាការងារនេះដែរក្រុមហ៊ុនបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងប្រតិភូបុគ្គលិករួមទាំងប្រធានផ្នែករហូតដល់មានការព្រមព្រៀងដូចខាងក្រោម៖

**ប្រការមួយ៖** និយោជក (គាគី "ក") រក្សាកិច្ចសន្យាការងាររបស់បុគ្គលិកនៅដដែល និងអត្ថប្រយោជន៍ផ្សេងៗដូចដែលមានចែងក្នុងកិច្ចសន្យាការងាររបស់សណ្ឋាគារ រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា។

**ប្រការពីរ៖** និយោជិត (គាគី "ខ") បានព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាការងាររបស់សណ្ឋាគារ រ៉ូយ៉ាល់អង្គរីសត និង ស្ប៉ា។

**ប្រការបី៖** និយោជក (គាគី "ក") ក្នុងអំឡុងពេលព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាការងារ សណ្ឋាគារមិនបានទូទាត់ប្រាក់បៀវត្សជូនកម្មករនិយោជិតឡើយ។

**ប្រការបួន៖** និយោជិត (គាគី "ខ") ក្នុងអំឡុងពេលការព្យួរកិច្ចសន្យាការងារ ក្នុងនាមជាតំណាងនិយោជិត និងបុគ្គលិកទាំងអស់បានដឹងលឺពីការព្យួរកិច្ចសន្យាការងារនេះ និងយល់ព្រមមិនទាមទាប្រាក់ឈ្នួលក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារពី និយោជក(គាគី "ក)ឡើយ។

ដើម្បីឲ្យប្រាកដ យើងខ្ញុំទាំងពីរភាគី សូមធ្វើការផ្ដិតស្នាមមេដៃស្ដាំទុកជាភស្តុតាង។

សៀមរាប ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០

ហត្ថលេខារបស់ គាគី "ក"

AN LONG AZ INVESTMENT CO.,LTD.

ផាត់ សុគន្ធ

ឈ្មោះ និងស្នាមមេដៃគាគី ខ

| | |
|---|---|
| ឈ្មោះ ជា សុខហេង<br>តួនាទី អនុប្រធានផ្នែកចុងភៅ | ឈ្មោះ យុត ឈាវ<br>តួនាទី អនុប្រធានផ្នែកផ្ទើរ |